រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៦៧/១៦ រ.ប.ក អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០១៦

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១៦ និងទិសដៅការងារ ខែកញ្ញា ឆ្នាំ២០១៦

(ពីថ្ងៃទី២៦/០៧/២០១៦ - ២៥/០៨/២០១៦)

យោងតាមផែនការសកម្មភាពនៃទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ដែលបានដាក់ចេញកាលពីខែកក្កដា ឆ្នាំ២០១៦ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលដៅចូលរួមចំណែកអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងលើកកម្ពស់សុខុមាលភាពជូនប្រជាពលរដ្ឋ ។ តាមរយៈ ការអនុវត្តផែនការ សកម្មភាពនៃទិសដៅការងារខាងលើ នៅក្នុងខែសីហានេះ យើងបានធ្វើការកត់សម្គាល់ទៅលើសភាពការណ៍ និង អនុវត្តការងារទទួលបានលទ្ធផលដូចខាងក្រោម ៖

### I. សភាពការណ៍គ្រឿងញៀន

ក្នុងខែសីហានេះ សកម្មភាពដឹកជញ្ជូនគ្រឿងញៀនពីតំបន់ត្រីកោណមាស ឆ្លងកាត់តាមប្រទេសឡាវ ចូលមក កម្ពុជា នៅតែបន្តកើតមានតាមបណ្តាច្រករបៀងព្រំដែននៃបណ្តាខេត្តនៅភាគឦសាន ។ ជាក់ស្តែង កម្លាំងរបស់មន្ទីរ ប្រឆាំងគ្រឿងញៀន, ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង ខេត្តព្រះសីហនុ និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តស្ទឹងត្រែង បង្រ្កាបបាន ០៥ ករណីធំៗ និងចាប់យក មេតំហ្វេតាមីន ICE - WY ហេរ៉ូអ៊ីន អ៊ិចស្តាស៊ី សរុបជិត ២៦ គ.ក្រ ស្មើនឹងជាង ៨២ % នៃបរិមាណគ្រឿងញៀនសរុបដែលបានចាប់យកនៅក្នុងខែនេះ ។ ជាមួយនេះ ក៏មាន ការចោរគ្រឿងញៀនប្រភេទ កូកាអ៊ីន ឆ្លងកាត់ច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មួយករណី ដែលបាននាំមក ពីប្រទេសប្រេស៊ីល ដោយបុរសជាជនជាតិ រ៉ូម៉ានី ។

ក្រៅពីនេះ សមត្ថកិច្ចនគរបាល និងកងរាជអាវុធហត្ថនៅតាមរាជធានី-ខេត្ត ក៏បានយកចិត្តទុកដាក់បង្ក្រាបបទ ល្មើសគ្រឿងញៀនយ៉ាងសកម្ម ទាំងបទល្មើសជួញដូរគ្រឿងញៀនក្នុងរូបភាពតូចតាច ក៏ដូចជាបទល្មើសប្រើប្រាស់ គ្រឿងញៀន ។

### II. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្រ្តី ប្រធាន អ.ជ.ប.គ.ញ បានបន្តដឹកនាំនិងណែនាំលើ ការងារជាគោលសំខាន់ៗ សម្រាប់អនុវត្តក្នុងខែសីហា និងការងារមួយចំនួនជាទិសដៅសម្រាប់អនុវត្តបន្តក្នុងខែកញ្ញា មានដូចតទៅ ៖



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមតំបន់មិនរៀបរយ, រោងចក្រ/សហគ្រាស, តំបន់គោលដៅទេសចរណ៍ ព្រមទាំងបង្កើនការបណ្ដុះបណ្ដាលក្រុមជនបង្គោល, រៀបចំក្រុមការងារចងក្រងបទពិសោធន៍ ជាឯកសារសម្រាប់អប់រំបង្ការការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន និងបន្តកម្មវិធីប្រឡងគូរគំនូរអប់រំពីបញ្ហាគ្រឿងញៀន ។

**២. ការព្យាបាល ស្ដារនីតិសម្បទា បណ្ដុះបណ្ដាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ត្រូវបន្តពិភាក្សាពីដំណើរការបង្កើតមណ្ឌលសុខភាពនៅក្នុងមណ្ឌលឱកាសខ្ញុំ, ប៉ុស្តិ៍សុខភាពនៅតាមមន្ទីរអប់រំកែប្រែនិងពន្ធនាគារ និងបន្តចុះសិក្សាស្វែងយល់ពីការងារព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងវិស័យរដ្ឋ និងឯកជន ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តបើកវគ្គបណ្ដុះបណ្ដាលដើម្បីពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមរយៈ ការបណ្ដុះបណ្ដាលតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) តាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិក (E-Learning) និងតាមរយៈការបណ្ដុះបណ្ដាលជំនាញផ្សេងៗទៀត ដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទនៅតាមក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ មន្ត្រីយោធានៅតាមភូមិភាគ និងមន្ត្រីអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិ ព្រមទាំងបន្តបណ្ដុះបណ្ដាលក្រុមជនបង្គោលក្នុងកងយោធពលខេមរភូមិន្ទ និងបន្តពង្រឹងយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** ត្រូវរៀបចំផែនការ និងយន្តការដាក់លាក់សម្រាប់គ្រប់គ្រង ត្រួតពិនិត្យតាមដានលើការនាំចូល និងការប្រើប្រាស់សារធាតុគីមីផ្សំ និងបន្តប្រមូលព័ត៌មានពាក់ព័ន្ធការប្រើប្រាស់សារធាតុញៀនថ្មីដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ព្រមទាំងត្រៀមបើកវគ្គបណ្ដុះបណ្ដាលស្តីពីការធ្វើតេស្តគ្រឿងញៀន និងសារធាតុគីមីផ្សំ, ការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** ជារួម ត្រូវបន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមក ជាមួយភាគីថៃ ឡាវ និងវៀតណាម ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ។ ជាមួយនេះ ត្រូវត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់កិច្ចប្រជុំទ្វេភាគី ត្រីភាគី កម្ពុជា វៀតណាម ឡាវ លើកទី១៦ ដែលនឹងត្រូវរៀបចំនៅកម្ពុជា តាមការប្ដូរវេនគ្នាធ្វើជាម្ចាស់ផ្ទះ ។ ជាមួយនេះ ត្រូវត្រៀមរៀបចំដំណើរទស្សនកិច្ច ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ អ.ជ.ប.គ.ញ ដែននឹងត្រូវអញ្ជើញទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា ៖** ត្រូវបន្តអនុវត្តនូវរាល់ខ្លឹមសារនៃកិច្ចព្រមព្រៀងនានា ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាមួយអង្គការ UNODC បណ្ដាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ជាពិសេសគម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) និងគម្រោងពង្រឹងប្រសិទ្ធភាពការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រូវធ្វើការបូកសរុប ដកពិសោធន៍ ពីលទ្ធផលដែលបានចុះជួយពង្រឹងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងជំរុញដល់រាជធានី-ខេត្ត ឱ្យរៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនដល់ថ្នាក់ខណ្ឌ ក្រុង ស្រុក សង្កាត់ ឃុំ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

តាមទិសដៅដែលបានដាក់ចេញកាលពីខែកក្កដា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១ ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ ៖**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បាន ៖

- សហការជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ បន្តការផលិតនូវបទយកការណ៍ខ្លីចំនួន២ ក្រោមប្រធានបទ ការថែទាំនិងការប្រយុទ្ធប្រឆាំងគ្រឿងញៀននៅតាមសហគមន៍ និងការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន
- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី រៀបចំនិងអញ្ជើញនាយកវិទ្យាល័យបុរី១០០ខ្នង, ប្រធានមណ្ឌលសុខភាពទឹកថ្លា និងនាយនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ទឹកថ្លា ដើម្បីចូលរួមផ្តល់កិច្ចសម្ភាសន៍នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ តាមកម្មវិធីនិងប្រធានបទ ដូចតទៅ ៖
  - កម្មវិធីព័ត៌មានពេលថ្ងៃ ស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងវិទ្យាល័យបុរី១០០ខ្នង
  - កម្មវិធីពេលរសៀល ស្តីពីការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍
  - ព័ត៌មានពេលល្ងាច ស្តីពីការអប់រំ បង្ការ និងដោះស្រាយបញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រសង្កាត់ទឹកថ្លា។

**១.២ ការងារអប់រំតាមសហគមន៍ ៖** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣, ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ០៤ បានចុះអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមមូលដ្ឋានរបស់ខ្លួន (ឈ្មោះក្រសួង-ស្ថាប័ន-ខេត្ត ដែលបានបញ្ជ្រាបខ្លឹមសារអប់រំ មាននៅទំព័រទី០១-០២ នៃតារាងឧបសម្ព័ន្ធ) ។ លទ្ធផលជារួម មហាជនដែលបានទៅទទួលសារអប់រំមានប្រមាណ **៥៤.៩៨៣** នាក់ ។

ក្នុងនោះ សកម្មភាពការងារអប់រំដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានអនុវត្តមានដូចខាងក្រោម ៖

- បានសហការជាមួយក្រសួងទេសចរណ៍ ចុះផ្សព្វផ្សាយការយល់ដឹងពីការបញ្ជ្រាបយេនឌ័រ និងការទប់ស្កាត់ការប្រើបំពានគ្រឿងញៀនក្នុងវិស័យទេសចរណ៍ នៅខេត្តព្រះវិហារ (ថ្ងៃទី២៨/៧/២០១៦ អ្នកចូលរួមប្រមាណ ៧៥ នាក់), ខេត្តប៉ៃលិន (ថ្ងៃទី២៥/៨/២០១៦ អ្នកចូលរួមប្រមាណ ៨៥ នាក់)
- បានសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចុះផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅខេត្តបាត់ដំបង (ថ្ងៃទី២៩/៧/២០១៦ អ្នកចូលរួមប្រមាណ ២៥៥ នាក់)
- បានបន្តចុះអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅសាលាសុវណ្ណភូមិ ក្នុងខណ្ឌពោធិ៍សែនជ័យ (ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស ចូលរួមប្រមាណ ១០០ នាក់)
- ចូលរួមធ្វើបទឧទ្ទេសនាមដល់នាយទាហាននៃទីបញ្ជាការដ្ឋានកងទ័ពជើងទឹក (ជ្រោយចង្វារ) ចំនួន ៣០០ នាក់ ស្តីពីបញ្ហាគ្រឿងញៀន កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦
- បានចូលរួមក្នុងពិធីបើកមហោស្រពប្រឡងចម្រៀងសម័យថ្នាក់ជាតិឆ្នាំ២០១៦ កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ (អ្នកចូលរួម ២៥០ នាក់)
- បានទទួលខិត្តប័ណ្ណអប់រំផ្សព្វផ្សាយចំនួន ៥០.០០០ សន្លឹក ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល.អូ.អិល.ស៊ី

- បាន និងកំពុងបន្តដំណើរការដំឡើងផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀន សម្រាប់ដាក់នៅតាមតំបន់ព្រំដែនកម្ពុជា-ឡាវ

- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែ សីហា ឆ្នាំ២០១៦ មានការចូលអានប្រមាណ **៤០.២១៦** ដង ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់ ៖

២.១.១. បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការប្រព្រឹត្តផ្លូវភេទ ក្នុងចំណោមក្រុមភេទទី៣ នៅប្រទេសកម្ពុជា ប្រចាំឆ្នាំ២០១៥ កាលពីថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០១៦ ។

២.១.២. បានចូលរួមកិច្ចប្រជុំក្រុមការងារចម្រុះរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីពីមេរោគអេដស៍ ជំងឺអេដស៍ កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

២.១.៣. បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំនាយកដ្ឋាន ០២ រូប ទៅចូលរួមកិច្ចប្រជុំ លើកទី៣ របស់គណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន នៅកន្លែងធ្វើការ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ (អ្នកចូលរួមសរុប ៦០ នាក់) ។

### ២.២. ការព្យាបាល និងស្តារនីតិសម្បទា

២.២.១. បានរៀបចំសិក្ខាសាលាកម្ពុជា-ថៃ ស្តីពីការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី១០-១២ ខែសីហា ឆ្នាំ២០១៦ នៅខេត្តព្រះសីហនុ ក្រោមគម្រោងគាំទ្រដោយការិយាល័យ នៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ អ្នកពាក់ព័ន្ធសរុប ៤៦ នាក់ (អគ្គលេខាធិការដ្ឋាន ០៦ រូប) ។

២.២.២. ក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទា បានចុះទស្សនកិច្ចស្វែងយល់ពីការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងវិស័យរដ្ឋ និងឯកជន ចាប់ពីថ្ងៃទី២៤-៣០ ខែកក្កដា ឆ្នាំ២០១៦ នៅខេត្តកំពង់ចាម ក្រចេះ និងខេត្តស្ទឹងត្រែង ។

២.២.៣. បានចាត់បញ្ជូនមន្ត្រីចំនួន ២១ នាក់ (មន្ត្រីអគ្គលេខាធិការដ្ឋាន ០៣ នាក់) ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២១-២៦ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។

២.២.៤. បានដំឡើងប៉ាណូផ្សព្វផ្សាយពីការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ក្នុងរាជធានីភ្នំពេញចំនួន ២១ កន្លែង ដូចមានក្នុងទំព័រទី ០៨ នៃតារាងឧបសម្ព័ន្ធ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៣.១.១. បានចូលរួមកិច្ចប្រជុំមន្ត្រីនគរបាលយុត្តិធម៌ប្រឆាំងបទល្មើសគ្រឿងញៀន ទាក់ទងនឹងនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការពុះញង់ឱ្យលក់ដោយខុសច្បាប់, វិធានការព្យាបាល និងស្តារនីតិសម្បទា និង មាត្រាច្បាប់មួយចំនួនពាក់ព័ន្ធបទល្មើសប្រើប្រាស់គ្រឿងញៀន និងការធ្វើកោសល្យវិច័យតាមបច្ចេកទេសវិទ្យា

សាស្ត្រ និងលទ្ធផល កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ នៅសាលាឧទ្ទរណ៍ ។

៣.១.២. បានចូលរួមកិច្ចប្រជុំក្រុមការងារវាយតម្លៃអញ្ញមញ្ញ កាលពីថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០១៦ ដើម្បីផ្តល់នូវទិដ្ឋភាពទូទៅអំពីដំណើរការវាយតម្លៃ និងពិភាក្សាលើចម្លើយតបសំណួរផ្នែកបច្ចេកទេសនិងប្រសិទ្ធភាព នៃការអនុវត្ត ការកំណត់ហានិភ័យ និងការរៀបចំកាលវិភាគចុះត្រួតពិនិត្យដល់ទីកន្លែង (អ្នកចូលរួម ១០០ នាក់) ។

៣.១.៣. បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) ដល់មន្ត្រីនគរបាលរាជធានីភ្នំពេញ ១២ រូប វគ្គទី៦/ឆ្នាំ២០១៦ ពីថ្ងៃទី២៥-២៩ ខែកក្កដា ឆ្នាំ ២០១៦ និងមន្ត្រី នៃអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ១២ រូប វគ្គទី៧/ឆ្នាំ២០១៦ ពីថ្ងៃទី២២-២៦/៨/២០១៦ ។

៣.១.៤. បានបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ៦៧ រូប ស្តីពីបញ្ហាគ្រឿងញៀន កាលពីថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០១៦ ក្នុងនោះ មកពីខេត្តប៉ៃលិន ៤៧ រូប, បាត់ដំបង ១០ រូប និងបន្ទាយមានជ័យ ១០ រូប ។

៣.១.៥. បានធ្វើការបូកសរុបលទ្ធផលការងារ របស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅតាមព្រំដែនជាប់ជាមួយប្រទេសថៃ ឡាវ និងវៀតណាម ចំនួន១៣កន្លែង (ប្រកព្រំ ខេត្តប៉ៃលិន ពុំមានរបាយការណ៍) ។ លទ្ធផលការងាររួម និងស្ថានភាពជាក់ស្តែងរបស់ការិយាល័យនីមួយៗ មាននៅទំព័រទី៣១ នៃតារាងឧបសម្ព័ន្ធ ។

៣.១.៦. បានបន្តការរៀបចំបញ្ជីទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលមន្ត្រីអនុវត្តន៍ច្បាប់បង្ក្រាបបាននាពេលកន្លងមក ។

៣.១.៧. បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ០២ រូប ទៅចូលរួមសិក្ខាសាលា Pre-Project ស្តីពីការពង្រឹងការិយាល័យទំនាក់ទំនងព្រំដែន (BLOs) តាមដងទន្លេមេគង្គ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ក្រោមការគាំទ្រដោយអគ្គរដ្ឋអាជ្ញាជាន់ខ្ពស់នៃសាធារណរដ្ឋកូរ៉េ ។

៣.១.៨. បានចាត់ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន ០២ រូប ទៅចូលរួមកិច្ចប្រជុំស្តីពីសុវត្ថិភាពសហគមន៍អាស៊ានប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ឆ្នាំ២០១៦-២០២៥ កាលពីថ្ងៃទី២១-២៣ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀន សរុប **៤០២** ករណី លើ ៣៦៦ ករណី នៃខែកក្កដា ឆ្នាំ២០១៦
- ជនសង្ស័យ ឃាត់ខ្លួន សរុប **៩២៥** នាក់ (ស្រី ៧១ នាក់) លើ ៨៤៤ នាក់ នៃខែកក្កដា ឆ្នាំ២០១៦

ក្នុងបទល្មើសគ្រឿងញៀនទាំង ៤០២ ករណី និងជនសង្ស័យទាំង ៩២៥ នាក់ ខាងលើគឺ ៖

- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចនគរបាល **៣០៧** ករណី, ជនសង្ស័យ **៦៤៧** នាក់ (ស្រី ៥០ នាក់)
- បទល្មើសគ្រឿងញៀនបង្ក្រាបដោយ សមត្ថកិច្ចកងរាជអាវុធហត្ថ **៩៥** ករណី, ជនសង្ស័យ **២៧៨** នាក់ (ស្រី ២១ នាក់)

ក្នុងចំនួនជនសង្ស័យ ៩២៥ នាក់ ខាងលើមាន ០៩ សញ្ជាតិគឺ ខ្មែរ ៩០៦ នាក់ (ស្រី ៦៨ នាក់), វៀតណាម ១១ នាក់ (ស្រី ០៣ នាក់), អូស្ត្រាលី ០១ នាក់ (ប្រុស), នីហ្សេរីយ៉ា ០១ នាក់ (ប្រុស), ឡាវ ០២ នាក់ (ប្រុស), ថៃ ០១ នាក់ (ប្រុស), អាមេរិក ០១ នាក់ (ប្រុស), អ៊ីតាលី ០១ នាក់ (ប្រុស), រ៉ូម៉ានី ០១ នាក់ (ប្រុស) ត្រូវបានកសាងសំណុំ រឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត

- **វត្ថុតាងគ្រឿងញៀនចាប់យក ៖** មេតំហ្វេតាមីនក្រាមម្សៅ (ICE) ១៥ គ.ក្រ ១៩១ ក្រាម ១៤ មេតំហ្វេតាមីនគ្រាប់ WY ៤ គ.ក្រ ៩៥៩ ក្រាម ១៦, អ៊ិចស្តាស៊ី ២៤៩ ក្រាម ៩៨, ហេរ៉ូអ៊ីន ៩៤៦ ក្រាម ៨៩, កូកាអ៊ីន ៤ គ.ក្រ ៩៦១ ក្រាម ៦៩, កញ្ឆាក្រៀម ៥ គ.ក្រ ០១៨ ក្រាម ៨០

**(សរុបគ្រឿងញៀនទាំងអស់មានចំនួន ៣១ គ.ក្រ ៣២៧ ក្រាម ៦៦)**

កត់សម្គាល់ ក្នុងបទល្មើសគ្រឿងញៀនសរុប ៤០២ ករណី មានបទល្មើសគ្រឿងញៀនដែលហូរចូលតាមច្រកព្រំដែននៃបណ្តាខេត្តនៅភាគឦសានចំនួន ៥ ករណីធំៗ ដែលត្រូវបានបង្ក្រាប និងចាប់យក មេតំហ្វេតាមីន ICE WY អ៊ិចស្តាស៊ី ហេរ៉ូអ៊ីន ប្រមាណ **២៥** គ.ក្រ **៩៦៩** ក្រាម **១៨** ។

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន ៖ រថយន្ត ១១ គ្រឿង, ម៉ូតូ ១៧៤ គ្រឿង, ប្រាក់កម្ពុជា ៨.៨៥៩.១០០ រៀល, ប្រាក់ថៃ ៦០០ បាត, ប្រាក់វៀតណាម ៣៥.០០០ ដុង, ប្រាក់អាមេរិក ១.៩២៩ ដុល្លារ

- ជនសង្ស័យចាប់តាមដីកា មាន ១៤ ដីកា = ជនសង្ស័យ ១៣ នាក់ (ស្រី ០២ នាក់) ។

ក្រៅពីការងារខាងលើ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានទទួលតេស្តរកសារធាតុញៀនក្នុងទឹកនោមពីការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀន (ONCB) ចំនួន ២០.០០០ តេស្ត កាលពីថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ។

## ៣.៣. លទ្ធផលកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

សំណាកសង្ស័យជាគ្រឿងញៀនដែលបានធ្វើកោសល្យវិច័យក្នុងខែសីហា ឆ្នាំ២០១៦ សរុប ១៦១ ករណី ស្មើនឹង ១៧៨ សំណាក ក្នុងនោះ ៖

- **សំណាក វិជ្ជមានសារធាតុញៀន** មាន ១៥៥ ករណី = ១៦៨ សំណាក (៩៤,៣៦ %) គឺ ៖
  - មេតំហ្វេតាមីន ICE ១៤៦ សំណាក = ៨២,០២ %
  - តេត្រាអ៊ីដ្រូកានណាប៊ីណុល ០២ សំណាក = ១,១២ %
  - មេតំហ្វេតាមីន WY ១៦ សំណាក = ៨,៩៨ % -នីមេតាហ្សេប៉ាម ០១ សំណាក = ០,៥៦ %
  - ហេរ៉ូអ៊ីន ២ សំណាក = ១,១២ % -MDMA ០១ សំណាក = ០,៥៦ %
- **សំណាក អវិជ្ជមានសារធាតុញៀន** ០៦ ករណី = ១០ សំណាក (៥,៦១ %)

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- សារធាតុគីមីផ្សំដែលមានក្នុងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានអនុញ្ញាតឱ្យនាំចូលនៅក្នុងខែសីហា ឆ្នាំ២០១៦នេះ សរុបមាន **២.១៧៦.៤០០** គ.ក្រ ក្នុងនោះ ៖
  - មានបទដ្ឋានបច្ចេកទេសឱ្យនាំចូលដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ចំនួន ១.៥៧៤.០០០ គ.ក្រ
  - មានអាជ្ញាប័ណ្ណឱ្យនាំចូលដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំនួន ៦០២.៤០០ គ.ក្រ

ដោយឡែក សារធាតុញៀនដែលនាំចូលដោយក្រសួងសុខាភិបាល និងមានក្នុងតារាងទី២ និងទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ ទំព័រទី៣៨ ។

- អគ្គលេខាធិការរង អ.ជ.ប.គ.ញ ០១ រូប បានអញ្ជើញចូលរួមកិច្ចប្រជុំ លើកទី១ របស់គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដើម្បីប្រកាសសមាសភាពនៃគណៈកម្មាធិការនេះ និងរៀបចំបទបង្ហាញស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យការផលិត ការនាំចូល ការនាំចេញ ការចែកចាយ និង

ស្តុកទុកទំនិញគ្រោះថ្នាក់ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ នៅវិទ្យាស្ថានស្តង់ដារកម្ពុជា ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. ឯកឧត្តម អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំប្រតិភូទៅចូលរួមក្នុងកិច្ចពិភាក្សាជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ពាក់ព័ន្ធនឹងជំនួយរបស់ភាគីថៃក្នុងការងារត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ ២០១៦ ។

៥.២. បានចូលរួមពិនិត្យលើខ្លឹមសារសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី (១៧.៨.២០១៦) និងបានទៅចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃ លើកទី១០ កាលពីថ្ងៃទី២៤-២៦ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៥.៣. បានទំនាក់ទំនងជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) និងកំពុងរៀបចំឯកសារសម្រាប់ការទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

៦.១. បានចាត់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ០២ រូប និងមន្ត្រីស្ថាប័នពាក់ព័ន្ធ ០១ រូប ទៅចូលរួមកិច្ចប្រជុំផែនការអាស៊ាន លើកទី២ ស្តីពីសុវត្ថិភាពសហគមន៍អាស៊ានប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ ឆ្នាំ២០១៦-២០២៥ កាលពីថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.២. បានចាត់មន្ត្រីទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីបញ្ហាគ្រឿងញៀន (ASOD) លើកទី៣៧ កាលពីថ្ងៃទី២៣-២៨ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.៣. បានទំនាក់ទំនងជាមួយអង្គការ UNODC និងរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការទៅចូលរួមសិក្ខាសាលាស្តីពីការពង្រឹងការប្រឆាំងភេរវករបរទេសនៅតំបន់ព្រំដែនជួរមុខក្នុងអនុតំបន់ទន្លេមេគង្គ ។

៦.៤. បានទំនាក់ទំនងជាមួយអង្គការ UNODC និងរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការទៅចូលរួមសិក្ខាសាលាស្តីពីការអភិវឌ្ឍផែនការសកម្មភាព MOU មហាអនុតំបន់ទន្លេមេគង្គ (SAP X) ។

៦.៥. បានទំនាក់ទំនងជាមួយអង្គការ UNODC និងរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី UNODC Global SMART Programme Regional ប្រចាំតំបន់ ។

៦.៦. បានទំនាក់ទំនងជាមួយការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) និងរៀបចំឯកសារសម្រាប់ការទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់គ្រឿងញៀនសម្រាប់ប្រទេសសមាជិក CICA (The Con- ference on Interaction and Confidence Building Measures in Asia . CICA) ។

៦.៧. បានទំនាក់ទំនងជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) និងរៀបចំឯកសារសម្រាប់ការទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន (Control of Drug Offences) ។

៦.៨. បាននិងកំពុងពិនិត្យលើសេចក្តីព្រាងសេចក្តីប្រកាសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី២៩ ដើម្បីផ្តល់យោបល់ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន ។

៦.៩. បានទំនាក់ទំនងជាមួយការិយាល័យរដ្ឋអាជ្ញាជាន់ខ្ពស់នៃសាធារណរដ្ឋកូរ៉េ និងរៀបចំឯកសារសម្រាប់ការទៅចូលរួមកិច្ចប្រជុំ លើកទី៣ ស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀននៃមជ្ឈមណ្ឌលព័ត៌មាននិងសម្របសម្រួលអាស៊ី-ប៉ាស៊ីហ្វិក (Asia Pacific Information and Coordination Center for Combating Drug Crimes. APICC) និងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន (ANTI-DRUG Liaison Officials'

Meeting for International Cooperation. ADLOMICO) លើកទី២៦ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ ។

### ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

៧.១. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានរៀបចំរួចរាល់ជាស្ថាពរនូវ សេចក្តីព្រាងប្រកាសអន្តរក្រសួងរវាងក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា " ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំបង្កើតមជ្ឈមណ្ឌលសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន " និង " សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្មអ្នកញៀនគ្រឿងញៀននៅមណ្ឌលបណ្តោះអាសន្ន " ដោយបានបញ្ជូនទៅក្រសួង-ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តពាក់ព័ន្ធ ជួយពិនិត្យនិងផ្តល់យោបល់ ។

៧.២. បានបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការកែសម្រួលសមាសភាពក្រុមការងារ និងក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

៧.៣. បាននិងកំពុងរៀបចំគណៈកម្មការតាមដាន ការប្រមូល ការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ។

៧.៤. បានបន្តការកែសម្រួលសេចក្តីព្រាងផែនការជាតិ ៣ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.៥. បាននិងកំពុងបន្តការរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៦. បាននិងកំពុងបន្តការកែសម្រួល សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៧.៧. បាននិងកំពុងបន្តចុះជួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញក្នុងការកសាងផែនការត្រួតពិនិត្យគ្រឿងញៀនសម្រាប់ថ្នាក់ខណ្ឌ និងសង្កាត់ (ជាពិសេសភូមិត្រពាំងឈូក) ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១៦

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

១.១. បន្តការចុះអប់រំផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ៖

- នៅតាមអនុវិទ្យាល័យ-វិទ្យាល័យក្នុងរាជធានីភ្នំពេញ និងបណ្តុះបណ្តាលសិស្សបង្គោលប្រចាំថ្នាក់
- នៅក្នុងវគ្គបណ្តុះបណ្តាលនិងផ្សព្វផ្សាយការយល់ដឹងពីការបញ្ច្រាបយេនឌ័រ ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនក្នុងវិស័យទេសចរណ៍
- នៅតាមរោងចក្រ សហគ្រាស ដោយសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- នៅតាមបណ្តាខេត្ត ដោយសហការជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- នៅក្នុងវគ្គបណ្តុះបណ្តាលនាយទាហានកងរាជអាវុធហត្ថ ថ្នាក់អនុសេនីយ៍ ១០០ នាក់ នាថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៦ ដោយសហការជាមួយក្រសួងការពារជាតិ ។

១.២. ត្រៀមរៀបចំ និងអញ្ជើញនាយកវិទ្យាល័យវត្តភ្នំ មណ្ឌលសុខភាពដូនពេញ និងនាយប៉ុស្តិ៍រដ្ឋបាលនគរបាលសង្កាត់ស្រះចក ផ្តល់បទសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី នាថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងកម្មវិធី ៖

- ព័ត៌មានពេលថ្ងៃ ស្តីពីសកម្មភាពអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងវិទ្យាល័យវត្តភ្នំ

- ព័ត៌មានពេលរសៀល ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ក្នុងមណ្ឌលសុខភាពដូនពេញ

- ព័ត៌មានពេលល្ងាច ស្តីពីការអប់រំ បង្ការ និងដោះស្រាយបញ្ហាគ្រឿងញៀនក្នុងភូមិសាស្ត្រសង្កាត់ស្រះចក។

១.៣. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.៤. បន្តសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និងបណ្តាក្រុមហ៊ុនឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន នៅក្នុងកម្មវិធីកម្សាន្តសប្បាយ និងកម្មវិធីប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនឯកជននានា ។

១.៥. បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៦. បន្តការរៀបចំដំឡើងផ្ទាំងប៉ាណូអប់រំពីបញ្ហាគ្រឿងញៀននៅតាមបណ្តាច្រកព្រំដែនកម្ពុជា-ឡាវ ។

១.៧. រៀបចំក្រុមការងារចងក្រងបទពិសោធន៍ និងឯកសារបង្ការការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

២.១. ត្រៀមទៅចូលរួមកិច្ចប្រជុំពិភាក្សាជាដៃគូស្តីពីការគាំពារគោលនយោបាយបង្ការ ទប់ស្កាត់គ្រឿងស្រវឹង នៅខេត្តឈៀងម៉ៃ ប្រទេសថៃ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៤-១៦ ខែកញ្ញា ឆ្នាំ២០១៦ ។

២.២. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាពណាដែលមានទំនុកចិត្ត ។

២.៣. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាពនៃយន្តការគ្រប់គ្រងមណ្ឌលបណ្តោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៤. បន្តជំរុញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីពង្រឹងយន្តការក្នុងការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

២.៥. ជំរុញក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឱ្យបង្កើតមណ្ឌលសង្គមកិច្ច នៅតាមបណ្តាខេត្ត ដែលមានអ្នកញៀនគ្រឿងញៀនច្រើន ។

២.៦. ជំរុញគណៈកម្មាធិការជាតិទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ឱ្យរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់ការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៧. ជំរុញគណៈកម្មាធិការជាតិទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ឱ្យរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមពន្ធនាគារ ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

៣.១. ត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការវិភាគគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៥/៧-០៥/៨/២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៣.២. ត្រៀមចាត់បញ្ជូនមន្ត្រីរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់គ្រឿងញៀនសម្រាប់ប្រទេសសមាជិក CICA (The Conference on Interaction and Confidence Building Measures in Asia . CICA) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៥-១៦ ខែកញ្ញា ឆ្នាំ២០១៦ នៅប្រទេសថៃ ។

៣.៣. បន្តបើកវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) និងតាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិក (E-Learning) ដល់មន្ត្រីអនុវត្តន៍ច្បាប់ ។

៣.៤. បន្តរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ៦៧ រូប ស្តីពីបញ្ហាគ្រឿងញៀន នៅថ្ងៃទី២៦-២៧ ខែសីហា ឆ្នាំ២០១៦ ដែលមកពីខេត្តស្ទឹងត្រែង ៤៧ រូប, ព្រះវិហារ ១០ រូប ឧត្តរមានជ័យ ១០ រូប ។

៣.៥. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន ០១ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យបទល្មើសគ្រឿងញៀន (Control of Drug Offences) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៨ ខែសីហា ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។

៣.៦. ត្រៀមចាត់បញ្ជូនមន្ត្រីទៅចូលរួមសិក្ខាសាលា Global SMART តំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ ។

៣.៧. បន្តការរៀបចំបញ្ជីទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសវត្ថុតាងពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ដែលមន្ត្រីអនុវត្តន៍ច្បាប់ បង្ក្រាបបាននាពេលកន្លងមក ។

៣.៨. ត្រៀមរៀបចំកិច្ចប្រជុំត្រួតពិនិត្យយន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅទូទាំងប្រទេស ។

## ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

៤.១. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់ ចំនួន ៣០ រូប ស្តីពីការអនុវត្តធ្វើតេស្តគ្រឿងញៀន និងសារធាតុគីមីផ្សំ ។

៤.២. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការស៊ើបអង្កេតការចរាចរសារធាតុគីមីផ្សំ និងមន្ទីរពិសោធន៍គ្រឿងញៀនលួចលាក់ ដល់មន្ត្រីអគ្គនាយកដ្ឋានគយនិងរដ្ឋាករ កងរាជអាវុធហត្ថ និងមន្ទីរប្រឆាំងគ្រឿងញៀន ។

៤.៣. ត្រៀមរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិស្តីពី ការបិទស្លាកសញ្ញា ការទុកដាក់ ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម (ដោយក្រសួងឧស្សាហកម្មនិងសិប្បកម្ម) ។

៤.៤. បន្តប្រមូលព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.៥. បន្តការរៀបចំកែសម្រួលសមាសភាពក្រុមការងារ និងក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

៥.១. ត្រៀមទទួលមន្ត្រីព័ត៌មានវិទ្យា (Information of Technology. IT) របស់ការិយាល័យនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) ដើម្បីពិភាក្សាក្នុងការរៀបចំបង្កើត Tele-Video Conference នៅអគ្គលេខា

ធិការដ្ឋាន អ.ជ.ប.គ.៣ ។

៥.២. ត្រៀមរៀបចំ និងទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូថៃ ដែលអញ្ជើញមកពិនិត្យស្ថានភាពភូមិសាស្ត្រនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ ដើម្បីរៀបចំការិយាល័យទំនាក់ទំនងព្រំដែន ។

៥.៣. ត្រៀមចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) កម្ពុជា-វៀតណាម លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសវៀតណាម ។

៥.៤. បន្តជំរុញការរៀបចំដំឡើងប៉ាណូអប់រំផ្សព្វផ្សាយ ពីបញ្ហាគ្រឿងញៀននៅតាមច្រកព្រំដែនកម្ពុជា-ឡាវ។

៥.៥. ត្រៀមសហការជាមួយប្រទេសថៃ ឡាវ និង វៀតណាម ក្នុងការរៀបចំផែនការកសាងភូមិ-ឃុំ គ្មានគ្រឿងញៀននៅតាមព្រំដែន ។

៥.៦. ត្រៀមរៀបចំដំណើរទស្សនកិច្ច ជូនគណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.៣ ដែលនឹងអញ្ជើញទៅកាន់សាធារណរដ្ឋសង្គមនិយមវៀតណាម ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.បគ.៣ ០២ រូប ទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី UNODC Global SMART Programme Regional ប្រចាំតំបន់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣០-៣១ ខែសីហា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទ ប្រទេសឡាវ ។

៦.២. ត្រៀមចាត់បញ្ជូនមន្ត្រី ០២ រូប ទៅប្រចាំការនៅមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ ដែលមានស្នាក់ការនៅខេត្តយូណាន ប្រទេសចិន ពីថ្ងៃទី០១/៩/ ដល់ថ្ងៃទី៣០/១១/ ២០១៦ ។

៦.៣. ត្រៀមទៅចូលរួមសិក្ខាសាលាស្តីពីការអភិវឌ្ឍផែនការសកម្មភាព MOU មហាអនុតំបន់ទន្លេមេគង្គ (SAP X) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី០៨-០៩/៩/២០១៦ នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.៤. ត្រៀមទៅចូលរួមកិច្ចប្រជុំ លើកទី៣ ស្តីពីការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀននៃមជ្ឈមណ្ឌលព័ត៌-មាននិងសម្របសម្រួលអាស៊ី-ប៉ាស៊ីហ្វិក (Asia Pacific Information and Coordination Center for Combating Drug Crimes. APICC) និងកិច្ចប្រជុំស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន (ANTI-DRUG Liaison Officials' Meeting for International Cooperation. ADLOMICO) លើកទី២៦ នៅទីក្រុងប៊ូសាន ប្រទេសកូរ៉េ ។

៦.៥. ត្រៀមចាត់មន្ត្រី ០១ រូប ដើម្បីទៅចូលរួមជាមួយសាកលវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រនយោបាយរបស់ប្រទេសចិន ក្នុងការរៀបចំឯកសារពាក់ព័ន្ធនឹងការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា សម្រាប់ការបោះពុម្ពផ្សព្វផ្សាយនៅក្នុងប្រទេសចិន និងបណ្តាប្រទេសអាស៊ាន ។

៦.៦. ត្រៀមពិធីចុះហត្ថលេខាលើគម្រោងត្រួតពិនិត្យកុងតឺន័រ របស់អង្គការ UNODC ។

៦.៧. បន្តសហការជាមួយអង្គការ UNODC ចុះទៅពិនិត្យស្ថានភាពភូមិសាស្ត្រនៅច្រកថ្មដា ស្រុកវាលវែង (ខេត្តពោធិ៍សាត់), ច្រកទ្វារអន្តរជាតិអូរយ៉ាដាវ (ខេត្តរតនគិរី) និង ច្រកអានសេះ (ខេត្តព្រះវិហារ) ដើម្បីពិនិត្យលទ្ធភាពក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. រៀបចំរបាយការណ៍បូកសរុបលទ្ធផល នៃការចុះពង្រឹងការអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាល លេខ ០១ បប ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការពង្រឹងវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. ត្រៀមរៀបចំកិច្ចប្រជុំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ។

៧.៣. បន្តការរៀបចំកែសម្រួលសមាសភាព នៃគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៧.៤. បានបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការកែសម្រួលសមាសភាពក្រុមការងារ និងក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារជាតុគីមីផ្សំ ។

៧.៥. បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៦. បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធនឹងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.៧. ត្រៀមចូលរួមសិក្ខាសាលាស្តីពីសមិទ្ធផលការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងផ្សព្វផ្សាយខ្លឹមសារសៀវភៅស្តីពីសេចក្តីផ្តើមនៃការតាក់តែងច្បាប់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ នៅក្រសួងយុត្តិធម៌ ។

៧.៨. បន្តការពិនិត្យលើសេចក្តីព្រាងប្រកាសអន្តរក្រសួង រវាងក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា " ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំបង្កើតមជ្ឈមណ្ឌលសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន " និង " សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការព្យាបាល ។

៧.៩. បន្តជំរុញឱ្យរាជធានី-ខេត្ត រៀបចំបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន នៅថ្នាក់ក្រោមខេត្ត (ថ្នាក់ក្រុង ខណ្ឌ ស្រុក សង្កាត់ ឃុំ ភូមិ) ។/.

**អគ្គលេខាធិការ**

**នាយឧត្តមសេនីយ៍ មាស វីរិទ្ធ**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ

" ដើម្បីជូនជ្រាប "
- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "
- ឯកសារ